**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

## ជូនចំពោះ

## លោកជំទាវ លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១២ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣ ដែលពិភពលោកប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់ការតស៊ូនិងគំរូវីរភាពរបស់នារីៗ ក្នុងការទាមទារសិទ្ធិសេរីភាព និងការគេចផុតពីទង្វើរំលោភបំពាននានា ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមចូលរួមអបអរសាទរ ដោយសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គលគ្រប់ប្រការ ជូនចំពោះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជានារីទាំងអស់ នៃក្រសួងមុខងារសាធារណៈ ទទួលបានសេចក្តីសុខ សុភមង្គល និងសម្រេបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ សុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២៣
**រដ្ឋមន្ត្រី**

**ហ៊ុន សុខា**